# បទដ្ឋាននៃការសិក្សា និងការធ្វើតេស្តរបស់រដ្ឋ

## តើអ្វីទៅជាបទដ្ឋាននៃការសិក្សា?

បទដ្ឋាននៃការសិក្សា K-12 របស់រដ្ឋ Washington កំណត់នូវអ្វីដែលសិស្សានុសិស្សទាំងអស់គួរដឹង និងអាចធ្វើបាននៅកម្រិតថ្នាក់នីមួយៗ។

## ហេតុអ្វីបានជាយើងត្រូវការបទដ្ឋានទាំងនេះ?

បទដ្ឋាននៃការសិក្សាស៊ីជម្រៅ តម្រូវឲ្យសិស្សធ្វើការត្រិះរិះពិចារណាឲ្យបានហ្មត់ចត់ និងប្រកបដោយគំនិតច្នៃប្រឌិតអំពីខ្លឹមសារអត្ថន័យ ជាជាងការចងចាំរត់មាត់—ដូច្នេះ ពួកគេត្រៀមលក្ខណៈជាស្រេចសម្រាប់អាជីព ការសិក្សានៅមហាវិទ្យាល័យ និងជីវិតរស់នៅបន្ទាប់ពីវិទ្យាល័យ។

## តើផ្នែកណាខ្លះនៃមាតិកាដែលមាន បទដ្ឋាននៃការសិក្សា?

ស្តង់ដារមាននៅក្នុងតំបន់មាតិកាចំនួន 13 រួមទាំងគណិតវិទ្យា សិល្បៈភាសាអង់គ្លេស វិទ្យាសាស្ត្រ បច្ចេកវិទ្យាអប់រំ និងភាសាពិភពលោក។

## ហេតុអ្វីបានជាយើងត្រូវមានការធ្វើតេស្តរបស់រដ្ឋ?

ការវាស់ស្ទង់ការរីកចម្រើនរបស់សិស្សលើជំនាញ និងចំណេះដឹងសំខាន់ៗគឺជាគន្លឹះសម្រាប់គ្រួសារ និងគ្រូៗ ដើម្បីដឹងថាតើសិស្សានុសិស្សមានលទ្ធភាពបញ្ចប់ការសិក្សាជាមួយនឹងជម្រើស ឬប្រសិនបើពួកគេអាចត្រូវការជំនួយបន្ថែម ឬឱកាសសិក្សាកម្រិតខ្ពស់។

ទិន្នន័យសាកល្បងក៏ជាឧបករណ៍សម្រាប់សាលារៀន មណ្ឌល និងរដ្ឋដើម្បីជួយអ្នកអប់រំបង្កើនការបង្រៀនដល់សិស្សទាំងអស់។ ការធ្វើតេស្តទូទាំងរដ្ឋក៏ជួយធានាថាសិស្សសាលាសាធារណៈទាំងអស់ មិនថាពួកគេទៅសាលារៀន មានលទ្ធភាពទទួលបានការអប់រំដែលមានគុណភាពនោះទេ។

## តើតេស្តរដ្ឋត្រូវបានតម្រូវដែរឬទេ?

ច្បាប់រដ្ឋ និងសហព័ន្ធតម្រូវឱ្យសិស្សត្រូវធ្វើតេស្តខាង៖

- **សិល្បៈភាសាអង់គ្លេស និងគណិតវិទ្យា៖**
- ថ្នាក់ទី 3 ដល់ទី 8 និងវិទ្យាល័យ (សិស្សធ្វើការវាយតម្លៃតុល្យភាពឈ្លាសវៃ (Smarter Balanced assessments)
- **វិទ្យាសាស្ត្រ៖** ថ្នាក់ទី 5 ទី 8 និង ទី 11

ដើម្បីដឹងថាតេស្តណាមួយដែលតម្រូវសម្រាប់ការបញ្ចប់វិទ្យាល័យ សូមចូលទៅកាន់គេហទំព័រ **www.WAtesting.com.**

**រឿងពិតកំពូលទាំង 5 យ៉ាង** — អំពីបទដ្ឋាន និការវាយតម្លៃការសិក្សា K-12 របស់រដ្ឋ Washington

### 1 *បំណិនជីវិតជាក់ស្តែង*

បទដ្ឋាន និងការវាយតម្លៃការរៀនសូត្ររបស់រដ្ឋវ៉ាស៊ីនតោនផ្តោតលើជំនាញពិតប្រាកដដែលសិស្សកំពុងរៀន និងអនុវត្តក្នុងថ្នាក់រៀនជារៀងរាល់ថ្ងៃដូចជាការដោះស្រាយបញ្ហា ការគិតស៊ីជម្រៅ និងការសរសេរ។ លើការវាយតម្លៃសិស្សបង្ហាញពីការងាររបស់គេ សរសេរ និងពន្យល់ចម្លើយរបស់ពួកគេដែលជាផ្នែកមួយនៃដំណើរការវាយតំលៃ ដូច្នេះការវាស់ស្ទង់ជំនាញ និងចំណេះដឹងដែលពួកគេនឹងត្រូវបន្តតាមវិថីអាជីពនៃជម្រើសរបស់ពួកគេ។

### 2 *ការបំបាត់នូវគម្លាត*

ការវាយតម្លៃជួយកំណត់គម្លាតភាពជោគជ័យ និងអាចឲ្យសាសានៅក្នុងតំបន់និងរដ្ឋផ្តល់ធនធានដោយផ្ទាល់ដែលពួកគេត្រូវការចាំបាច់បំផុត។

### 3 *ការធ្វើតេស្តគឺគ្រាន់តែជាការវាស់ស្ទង់មួយប៉ុណ្ណោះ*

ការធ្វើតេស្តថ្នាក់រដ្ឋ គឺជាសូចនាករមួយក្នុងចំណោមសូចនាករជាច្រើន រួមជាមួយនឹងកាតរបាយការណ៍ ការផ្តល់មតិកែលម្អរបស់គ្រូបង្រៀន និងកិច្ចការក្នុងថ្នាក់រៀនដែលត្រូវបានប្រើប្រាស់ដើម្បីបង្កើតជារូបរាងពេញលេញនៃការរីកចម្រើនរបស់សិស្សនៅក្នុងសាលារៀន។

### 4 *រឿងដែលត្រឹមត្រូវ*

បទដ្ឋាននៃការសិក្សានៅក្នុងរដ្ឋ Washington និងការវាយតម្លៃដែលស្រប់ទៅតាមប្រព័ន្ធ ត្រូវបានបង្កើតឡើងដើម្បីត្រៀមរៀបចំសិស្សសម្រាប់ថ្នាក់មហាវិទ្យាល័យ ការងារ និងជីវិតរស់នៅ។

### 5 *អាចចូលប្រើបានសម្រាប់សិស្សទាំងអស់*

តេស្ត Smarter Balanced ត្រូវបានរៀបចំឡើងទៅតាមសិស្សានុសិស្សទាំងអស់ រួមទាំងសិស្សដែលមានពិការភាព និងសិស្សរៀនភាសាអង់គ្លេសផងដែរ។

**ស្វែងយល់បន្ថែម!**

***បទដ្ឋាននៃការសិក្សា***
**bit.ly/StateStandards**
ឬផ្ញើអ៊ីម៉ែលទៅកាន់ **CoreStandards@k12.wa.us**

***ការធ្វើតេស្តរបស់រដ្ឋ***
**www.WAtesting.com**
ឬ អ៊ីម៉ែល **StateTesting@k12.wa.us**

***គាំទ្រសិស្សរបស់អ្នក***
សាលាល្អៗ៖
**http://bit.ly/2tRyZoO**